# ប្រភេទពោធិសត្វ



**ពោធិសត្ត** (សំ.), (បា.) (អានថា : ពោធិស័ត) អ្នកដែលមានចិត្ត ឬមានសេចក្ដីប្រាថ្នាជាប់នៅក្នុងពោធិ (គឺការត្រាស់ដឹងលោកុត្តរធម៌) បើទុកជាភ្ញាត់ជាតិទៅកើតជាតិរច្ឆាន ក៏គង់នៅហៅថាពោធិសត្វដែរ ព្រោះមានបំណងនោះជាប់នៅមិនបាត់ ឬអស់សេចក្ដីប្រាថ្នា ឬក៏លែងចង់ឡើយ ។

ពាក្យថា **ពោធិសត្វ** នេះ ជាទូទៅ គេតែងតែយល់ថា អ្នកដែលសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធតែម្យ៉ាង តែបើយើងសង្កេតពិនិត្យមើលការសម្ដែងរបស់អដ្ឋកថា និងដីកាទាំងឡាយវិញ បញ្ជាក់ឲ្យឃើញថា ពាក្យថា **ពោធិសត្វ** នេះ មានដល់ទៅ ៣ ប្រភេទ មិនមែនសំដៅយកតែអ្នកសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធតែម្យ៉ាងនោះទេ គឺមានបែកចែកជា ៣ ប្រភេទ គឺ ៖

១. ***សព្វញ្ញូពោធិសត្វ*** *ឬ* ***មហាពោធិសត្វ*** *ពោធិសត្វដែលសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។*

២. ***បច្ចេកពោធិសត្វ*** *ពោធិសត្វដែលសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះបច្ចេកពុទ្ធ ។*

៣. ***សាវកពោធិសត្វ*** *ពោធិសត្វដែលសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ជាព្រះសាវកពុទ្ធ ។*

## ១. សព្វញ្ញូពោធិសត្វចែកជា ៣ ប្រភេទ

១.១. *ព្រះពោធិសត្វឧគ្ឃដិតញ្ញូ* មាននាមថា **បញ្ញាធិក** ។
១.២. *ព្រះពោធិសត្វវិបច្ចិតញ្ញូ* មាននាមថា **សទ្ធាធិក** ។
១.៣. *ព្រះពោធិសត្វនេយ្យៈ* មាននាមថា **វិរិយាធិក** ។

*ព្រះសព្វញ្ញូពោធិសត្វទាំង ៣ ប្រភេទ ដូចពោលមកនេះ មានអត្ថន័យដូចតទៅ ៖*

***ឧគ្ឃដិតញ្ញូពោធិសត្វ*** *គឺជាព្រះពោធិសត្វដែលសាងបារមីក្រាស់ដោយបញ្ញា ។ បន្ទាប់ពីបានព្យាករណ៍ពីព្រះពុទ្ធអង្គណាមួយមុនគេមក ព្រះពោធិសត្វប្រភេទនេះ ត្រូវបំពេញបារមីបន្ថែមចំនួន ៤ អសង្ខៃយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។*

***វិបច្ចិតញ្ញូពោធិសត្វ*** *គឺជាព្រះពោធិសត្វដែលសាងបារមីក្រាស់ដោយសទ្ធា ។ បន្ទាប់ពីបានព្យាករណ៍ពីព្រះពុទ្ធអង្គណាមួយមុនគេមក ព្រះពោធិសត្វប្រភេទនេះត្រូវបំពេញបារមីបន្ថែមចំនួន ៨ អសង្ខៃយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។*

***នេយ្យពោធិសត្វ*** *គឺជាព្រះពោធិសត្វដែលសាងបារមីក្រាស់ដោយវីរិយៈ ។ បន្ទាប់ពីបានព្យាករណ៍ពីព្រះពុទ្ធអង្គណាមួយមុនគេមក ព្រះពោធិសត្វប្រភេទនេះត្រូវបំពេញបារមីបន្ថែមចំនួន ១៦ អសង្ខេយ្យ ១ សែនកប្ប ទើបបានចាក់ធ្លុះនូវសម្មាសម្ពោធិញ្ញាណ ។*

*ម្យ៉ាងទៀត គម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ឯកកនិបាត បានបញ្ជាក់ថា ៖*

*ព្រះពុទ្ធទ្រង់មានសព្វញ្ញុតញ្ញាណត្រាស់ដឹង ព្រោះទ្រង់បំពេញនូវបារមីទាំងឡាយអស់ ៤ អសង្ខេយ្យ ១ សែនកប្បខ្លះ ៨ អសង្ខេយ្យ ១ សែនកប្បខ្លះ ១៦ អសង្ខេយ្យ ១ សែនកប្បខ្លះ ហើយទ្រង់ញាំញីនូវមារ ទើបមានព្រះនាមថា សព្វញ្ញុពុទ្ធ ។*

*ព្រះអដ្ឋកថាចារ្យបញ្ជាក់ក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាចរិយាបិដកថា ៖*

*ព្រះពោធិសត្វថ្នាក់ទាបបំផុត លោកត្រូវបំពេញបារមីមានចំនួន ៤ អសង្ខេយ្យ ១ សែនមហាកប្ប, ថ្នាក់កណ្ដាល លោកត្រូវបំពេញបារមីមានចំនួន ៨ អសង្ខេយ្យ ១ សែនមហាកប្ប, ថ្នាក់ខ្ពស់ លោកត្រូវបំពេញបារមីមានចំនួន ១៦ អសង្ខេយ្យ និង ១ សែនមហា-កប្ប ។*

*ព្រះពោធិសត្វមានការបំពេញបារមីខុសគ្នាយ៉ាងនេះឯង ។*

*ហេតុដូចម្ដេច បានជាព្រះពោធិសត្វ លោកបំពេញបារមីធម៌ខុសកាលគ្នាយ៉ាងនេះ ?*

*នៅក្នុងសេចក្ដីនេះ លោកបញ្ជាក់ក្នុងអដ្ឋកថាថា ៖*

*ធម្មតាបុគ្គលទាំងឡាយដែលបានឈ្មោះថាជា* ***និយតពោធិសត្វ*** *ត្រូវប្រជុំរួមប្រកបដោយធម៌ទាំង ៨ ក្នុងពេលជួបព្រះសម្មាសម្ពុទ្ធអង្គណាមួយផ្ទាល់ ។ ក្នុងធម៌ទាំង ៨ នោះ មានធម៌ទី ៣ គឺ* **ហេតុ** *សំដៅដល់បុគ្គលដែលមានឧបនិស្ស័យក្នុងអរហត្តផល «ភាពជាព្រះអរហន្ត» ក្នុងអត្តភាពនោះ ។*

*សមដូចក្នុងគម្ពីរបរមត្ថជោតិកា អដ្ឋកថា សុត្តនិបាត បានបញ្ជាក់ថា ៖*

*ឧបនិស្សយសម្បត្តិនៃអរហត្ត ឈ្មោះថា ហេតុ ។ មែនពិត បុគ្គលណាមួយមានសេចក្ដីព្យាយាមអាចចាក់ធ្លុះនូវព្រះអរហត្ត ក្នុងអត្តភាពនោះឯង ការតាំងប្រាថ្នានូវពុទ្ធភូមិ តែងសម្រេចដល់បុគ្គលអ្នកដល់ព្រមដោយហេតុគឺអរហត្តនោះ, មិនសម្រេចដល់បុគ្គលដទៃដែលមិនមានហេតុនោះឡើយ ។ តាមធម្មនិយាមនៃព្រះធម៌ បុគ្គលដែលត្រូវសម្រេចជាព្រះអរហន្ត មាន ៣ ពួកគឺ ឧគ្ឃដិតញ្ញូបុគ្គល១ វិបច្ចិតញ្ញូបុគ្គល១ នេយ្យបុគ្គល១ ។ ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជាឧគ្ឃដិតញ្ញូបុគ្គល លោកស្ដាប់ព្រះធម៌ចំពោះព្រះភក្រ្តព្រះសម្ពុទ្ធអង្គណាមួយប្រកបដោយគាថា៤បទ នៅមិនទាន់ចប់បទគាថាទី៣ លោកអាចសម្រេចជាព្រះអរហន្ត មួយអន្លើដោយអភិញ្ញា៦ បដិសម្ភិទា៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ តែលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងក្នុងការសម្រេចសម្មាសម្ពោធិញ្ញាណវិញ ព្រោះហេតុនោះ ពោធិសត្វអង្គនោះ មានឈ្មោះថា* ***ឧគ្ឃដិតញ្ញូពោធិសត្វ*** *ត្រូវបំពេញពុទ្ធការកធម៌ត្រឹមចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។*

*ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជាវិបច្ចិតញ្ញូបុគ្គល លោកស្ដាប់ព្រះធម៌ចំពោះព្រះភក្រ្តព្រះសម្ពុទ្ធអង្គណាមួយប្រកបដោយគាថា៤បទ នៅមិនទាន់ចប់បទគាថាទី៤ លោកអាចសម្រេចជាព្រះអរហន្តមួយអន្លើដោយអភិញ្ញា៦ បដិសម្ភិទា៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ តែលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងក្នុងការសម្រេចសម្មាសម្ពោធិញ្ញាណវិញ ព្រោះហេតុនោះ ពោធិសត្វអង្គនោះមានឈ្មោះថា* ***វិបច្ចិតញ្ញូពោធិសត្វ*** *ត្រូវបំពេញពុទ្ធការកធម៌ត្រឹមចំនួន ៨ អសង្ខេយ្យ ១ សែនកប្ប នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។*

*ប្រសិនបើក្នុងអត្តភាពនោះ ព្រះពោធិសត្វជានេយ្យបុគ្គល លោកស្ដាប់ព្រះធម៌ចំពោះព្រះភក្រ្តព្រះសម្ពុទ្ធអង្គណាមួយប្រកបដោយគាថា៤បទ លុះត្រាតែចប់បទគាថាទី៤ លោក*

*អាចសម្រេចជាព្រះអរហន្តមួយអន្ទើដោយអភិញ្ញា៦ បដិសម្ភិទា៤ ប្រសិនបើមានបំណងជាសាវកពោធិញ្ញាណ តែលោកមិនបង្អោនទៅក្នុងសាវកពោធិញ្ញាណ បែរត្រឡប់មានបំណងក្នុងការសម្រេចសម្មាសម្ពោធិញ្ញាណវិញ ។ ព្រោះហេតុនោះ ពោធិសត្វអង្គនោះ មានឈ្មោះថា* ***នេយ្យពោធិសត្វ*** *ត្រូវបំពេញពុទ្ធការកធម៌ត្រឹមចំនួន១៦ អសង្ខ្វៃយ្យ ១ សែនកប្បនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។*

## ព្រះសព្វញ្ញុពោធិសត្វដល់ព្រមដោយអភិនីហារ ៨ ប្រការ

*មុននឹងបុគ្គលត្រូវបានទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធជាលើកទី១ ដែលជាលក្ខណៈ ញ៉ាំងឲ្យក្លាយជា និយតពោធិសត្វ បុគ្គលនោះត្រូវតែប្រកបដោយអង្គ ៨ ហៅថា «****អដ្ឋសមោធាន****» គឺការប្រជុំរួមធម៌ទាំង៨ ។ ធម៌ទាំង៨នេះមានសម្តែងនៅក្នុងខុទ្ទកនិកាយពុទ្ធវំសថា*

| | |
|---|---|
| មនុស្សត្តំ លិង្គសម្បត្តិ | ហេតុ សត្ថារទស្សនំ |
| បព្ពជ្ជា គុណសម្បត្តិ | អធិការោ ច ឆន្ទតា |
| អដ្ឋធម្មសមោធានា | អភិនីហារោ សមិជ្ឈតិ។ |

*និយតពោធិសត្វត្រូវសម្រេចដោយអភិនីហារប្រជុំដោយធម៌ទាំងឡាយ ៨ គឺ ៖ ភាពជាមនុស្ស១ ដល់ព្រមដោយភេទគឺបុរស១ ដល់ព្រមដោយហេតុដែលអាចសម្រេចអរហន្តបានក្នុងជាតិនេះគឺឧបនិស្សយសម្បត្តិ១ បានជួបព្រះសម្មាសម្ពុទ្ធដោយផ្ទាល់១ បព្វជ្ជាជាតាបស ឬភិក្ខុសង្ឃ១ ដល់ព្រមដោយគុណធម៌ គឺបានសម្រេចនូវអភិញ្ញា១ បានធ្វើយ៉ាងក្រៃលែងដើម្បីបូជាព្រះពុទ្ធ១ មានឆន្ទៈយ៉ាងខ្លាំងក្លាដើម្បីបានត្រាស់ជាព្រះពុទ្ធ១ ។*

# ២. ព្រះបច្ចេកពុទ្ធពោធិសត្វមាន ៣ ប្រភេទ

**បច្ចេកពុទ្ធ** *(ប៉ុ.) [បច្ចេក+ពុធិ+ត] អ្នកត្រាស់ដឹងដោយចំណែកមួយ ។ បច្ចេកពុទ្ធ (ន.) [ប៉ុច-ចេកៈពុទ្ធ] លោកអ្នកត្រាស់ដឹងចំពោះបានតែខ្លួនមួយ សម្ដែងធម៌ប្រៀនប្រដៅអ្នកដទៃផងមិនកើត : ព្រះបច្ចេកពុទ្ធ ។*

**២.១. បញ្ញាធិកាបច្ចេកពុទ្ធ** *បច្ចេកពោធិសត្វដែលក្រៃលែងដោយបញ្ញា ត្រូវបំពេញបារមី ចំនួន ២ អសង្ខេយ្យ ១ សែនកប្ប ទើបបានត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។*

**២.២. សទ្ធាធិកាបច្ចេកពុទ្ធ** *បច្ចេកពោធិសត្វដែលក្រៃលែងដោយសទ្ធា ត្រូវបំពេញបារមី ច្រើនជាង ២ អសង្ខេយ្យ ១ សែនកប្ប តែមិនដល់ ៣ អសង្ខេយ្យទេ ទើបបានត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។*

**២.៣. វីរិយាធិកាបច្ចេកពុទ្ធ** *បច្ចេកពោធិសត្វដែលក្រៃលែងដោយវីរិយៈ ត្រូវបំពេញបារមី ច្រើនជាងចំនួនរបស់សទ្ធាធិកបច្ចេកពុទ្ធ តែមិនដល់ ៣ អសង្ខេយ្យទេ ទើបបានត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។*

*(អត្ថន័យចាក បរមត្ថទីបនី អដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា និទានគាថាវណ្ណនា)*

## ព្រះបច្ចេកពោធិសត្វដល់ព្រមដោយអភិនីហារ ៥ ប្រការ

មនុស្សត្តំ លិង្គសម្បត្តិ    វិគតាសវទស្សនំ
អធិកាហោ ឆន្ទតា ឯតេ    អភិនីហារការណា។

*ហេតុនៃអភិនីហារទាំងឡាយនោះគឺ ភាពជាមនុស្ស ១ ដល់ព្រមដោយភេទ ១ បានឃើញអ្នកប្រាសចាកអាសវៈ ១ អធិការៈ (បានធ្វើយ៉ាងក្រៃលែង) ១ មានឆន្ទៈបំណងប្រាថ្នា ១ ។*

*(បរមត្ថទីបនី អដ្ឋកថា សុត្តន្តបិដក ថេរគាថា និទានគាថាវណ្ណនា)*

## ៣. ព្រះសាវកពោធិសត្វ មាន ៣ ប្រភេទ

**សាវកពោធិសត្វ** *ពោធិសត្វដែលសន្សំបុណ្យបារមីដើម្បីឲ្យបានត្រាស់ជាព្រះសាវកពុទ្ធ ។*

៣.១. **អគ្គសាវក** *សាវកពោធិសត្វអង្គនេះត្រូវបំពេញបារមី ១ អសង្ខេយ្យ ១ សែនកប្ប ទើបបានត្រាស់ដឹងសាវកពោធិញ្ញាណ ។*

៣.២. **អសីតិមហាសាវក** *សាវកពោធិសត្វអង្គនេះត្រូវបំពេញបារមី ១ សែនកប្ប ទើបបានត្រាស់ដឹងសាវកពោធិញ្ញាណ ។*

៣.៣. **បកតិសាវក** *សាវកពោធិសត្វអង្គនេះបំពេញបារមី តិច ឬ ច្រើន មិនមានកំណត់ច្បាស់លាស់ បានត្រាស់ដឹងសាវកពោធិញ្ញាណ ។*

### ព្រះសាវកពោធិសត្វដល់ព្រមដោយអភិនីហារ ២ ប្រការ

១. **អធិការោ** *អធិការៈ (មានធ្វើយ៉ាងក្រៃលែង)*

២. **ឆន្ទតា** *មានឆន្ទៈបំណងប្រាថ្នា ។*

*(បរមត្ថទីបនី អដ្ឋកថា សុត្តន្តបិដក ថេរគាថា និទានគាថាវណ្ណនា)*

*ដោយបណ្ឌិត កុល ផេង*